**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ០៨៦/១៧

*រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧*

# គោលការណ៍ណែនាំ

## ស្តីពី

## បែបបទនិងនីតិវិធីសម្រាប់ការស្នើសុំធានាករណីនៃការពពោះជំនួស ដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស

(អនុវត្តត្រឹមថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៨)

**យោង៖** សេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ២៥៣សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៧ ស្តីពី«គោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួសដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស» ។

ដើម្បីដោះស្រាយបាតុភាពនៃការពរពោះជំនួស ក្នុងតំណាក់កាលនេះ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង លេខ២៥៣សជណ រហូតដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** សូមដាក់ចេញនូវគោលការណ៍ណែនាំ អំពីបែបបទនិងនីតិវិធីមួយចំនួន ដើម្បីសម្រួលដល់ការស្នើសុំពីឪពុករបស់ទារក ជាជនបរទេស ដែលមានបំណងយកកូនទៅចិញ្ចឹមបីបាច់ នៅឯប្រទេសរបស់ខ្លួន ដូចខាងក្រោម៖

**បែបបទ និងនីតិវិធីនៃការដាក់ពាក្យស្នើសុំ៖**

១. ជនបរទេសដែលអះអាងថាជាឪពុក ត្រូវដាក់សំណុំលិខិតស្នើសុំតាមរយៈស្ថានទូត ឬស្ថានតំណាង របស់ខ្លួន ប្រចាំនៅកម្ពុជា ដែលឯកសារនីមួយៗ មានសុពលភាពយ៉ាងយូរ០៦ ខែ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ ។ ឯកសារទាំងនេះ ត្រូវមានការបញ្ជាក់ភាពត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬស្ថានទូតនៃប្រទេសសាមីរបស់អ្នកស្នើសុំ ។

ឯកសារ មានជាអាទិ៍៖

- ✓ ពាក្យស្នើសុំ មានបិទរូបថតសាមីខ្លួនអ្នកស្នើសុំ និងសហព័ទ្ធ (បើមាន)
- ✓ លិខិតបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសដែលមានចំណងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា

- ✓ របាយការណ៍សង្ខេបអំពីស្ថានភាពគ្រួសារ ដែលមានការទទួលស្គាល់ពីក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសសាមី ដោយបញ្ជាក់ពីមូលហេតុ និងគោលបំណងនៃការពពោះជំនួសកន្លងមក
- ✓ លិខិតបញ្ជាក់ថាគ្មានទោស (ឬលិខិតថ្កោលទោស) ចេញដោយអាជ្ញាធរនៃប្រទេសកំណើត និង/ឬ ប្រទេសដែលសាមីខ្លួនអ្នកស្នើសុំរស់នៅអចិន្ត្រៃយ៍ បីឆ្នាំចុងក្រោយ
- ✓ សេចក្តីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ ឬប្រាក់ចំណូល ឬទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ✓ កិច្ចសន្យារបស់សាមីអ្នកស្នើសុំ ស្តីពីការផ្តល់ព័ត៌មានពីការវិវត្តន៍លូតលាស់កាយសម្បទា ប្រាជ្ញាស្មារតី និងការអភិវឌ្ឍផ្សេងៗ ក្រោមការទទួលខុសត្រូវរបស់ខ្លួនរហូតដល់វ័យ ១៨ឆ្នាំ តាមរយៈស្ថានទូតកម្ពុជាប្រចាំប្រទេសសាមី ជាទៀងទាត់មួយឆ្នាំម្តង និងអាចមានរបាយការណ៍ពិសេស បើសាមីខ្លួនមានភាពចាំបាច់ក្នុងការផ្តល់ព័ត៌មាន
- ✓ លិខិតឆ្លងដែន (និងទិដ្ឋាការដែលមានសុពលភាព)របស់សាមីខ្លួនអ្នកស្នើសុំ
- ✓ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណស្ត្រីពពោះ(ជនជាតិខ្មែរ) (ឬលើសពីមួយឯកសារ ក្នុងករណីមិនមានទិន្នន័យច្បាស់លាស់)
- ✓ សំបុត្រកំណើតទារក។

២. ទន្ទឹមនឹងនេះ បុរសដែលអះអាងថាជាឪពុក ត្រូវដាក់ពាក្យទៅ តុលាការ ភ្ជាប់ដោយភស្តុតាងកោសលវិច្ច័យDNA ដើម្បីសុំការសម្រេចពីតុលាការ បញ្ជាក់អំពីបិតុភាព និងការផ្ទេរសិទ្ធិអាណាព្យាបាលលើទារកពីស្ត្រីពពោះទៅឲ្យខ្លួនជាជនបរទេស ទើបមានសិទ្ធិនាំទារកទៅចិញ្ចឹមនៅប្រទេសខ្លួនបាន ។ លើសពីនេះទៅទៀត សាមីខ្លួនត្រូវមានឯកសារបញ្ជាក់សញ្ជាតិរបស់ទារក ចេញដោយអាជ្ញាធរប្រទេសសាមីជនបរទេសផងដែរ ។

៣. ស្ថានទូតនៃប្រទេសសាមី ត្រូវធ្វើលិខិតបញ្ជូនសំណុំឯកសារទាំងអស់នេះ ទៅរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីពិនិត្យ និងផ្តល់យោបល់ជូនទៅក្រសួងមហាផ្ទៃ ។

៤. ការិយាល័យទទួលឯកសារនៃក្រសួងមហាផ្ទៃ ទទួលបានសំណុំលិខិតដែលបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ត្រូវចុះបញ្ជី ពិនិត្យភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃសំណុំឯកសារ ព្រមទាំងលក្ខ័ណ្ឌសមស្របទាំងឡាយ ដែលអាចអនុញ្ញាតតាមសំណើសុំ ឬត្រូវឲ្យសាមីខ្លួនបំពេញបន្ថែមតាមការចាំបាច់ ។

៥. ក្នុងករណីដែលសេចក្តីសម្រេចរបស់តុលាការអំពីបិតុភាព ខុសពីទិន្នន័យដែលមានក្នុងសំបុត្រ កំណើតដែលបានធ្វើរួចហើយ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវចេញសំបុត្រកំណើតជាថ្មីឲ្យទារក ដោយមោឃភាពសំបុត្រកំណើតចាស់ និងរាល់សេចក្តីចម្លងសំបុត្រកំណើតដែលបានធ្វើរួចហើយ ។

៦. ក្នុងករណីដែលមានល័ក្ខខ័ណ្ឌសមស្រប ក្រសួងមហាផ្ទៃចេញស.ជុ.ណ អនុញ្ញាតឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ផ្តល់ទិដ្ឋាការចេញ ដើម្បីឲ្យសាម៉ីខ្លួនអ្នកស្នើសុំអាចនាំទារកចេញទៅប្រទេសសាមីតាមផ្លូវច្បាប់ ។

បែបបទ និងនីតិវិធីនេះ នឹងត្រូវបានអនុវត្តចំពោះតែទារកដែលមានកំណើតដោយការពពោះ ជំនួស ក្នុងចន្លោះពេលដែលកំណត់ខាងលើ តែប៉ុណ្ណោះ ។ ចំពោះករណីដែលខុសពីការកំណត់នេះ នឹងត្រូវពិនិត្យដោះស្រាយតាមច្បាប់ ជាធរមាន ។

ទន្ទឹមនឹងនេះ ៖

## ក្រសួងសុខាភិបាល

- គប្បីធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ អំពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ២៥៣ ស.ជ.ណ ដោយធ្វើការត្រួតពិនិត្យ ណែនាំជាប្រចាំ ដល់គ្រឹះស្ថាន វេជ្ជសាស្ត្រសុខាភិបាល ទាំងរដ្ឋ ទាំងឯកជនដែលពាក់ព័ន្ធ ព្រមទាំងលិខិតក្រសួងសុខាភិបាលលេខ០២៥ អបស.មព ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៧ ស្តីពី ការមិនអនុញ្ញាតឲ្យធ្វើការផ្សាំ ឬការជួញដូរកោសិកា ជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិតញី ឬឈ្មោល ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

## ក្រសួងមហាផ្ទៃ

- ពង្រីកការផ្សព្វផ្សាយអំពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ២៥៣ស.ជ.ណ ព្រមទាំងជូនដំណឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានវិធានការណែនាំអំពីនីតិវិធីក្នុងតំណាក់កាលបណ្តោះអាសន្ន ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការចេញសំបុត្រអត្រានុកូលដ្ឋានដល់ទារក ដែលកើតដោយពលរដ្ឋខ្មែរ និងជនបរទេស និងបទដ្ឋានពាក់ព័ន្ធផ្សេងៗ ដែលគេអាចយកទៅប្រើប្រាស់ក្នុងគោលដៅខុសច្បាប់ ។
- ពង្រឹងការត្រួតពិនិត្យតាមបណ្តាច្រកទ្វារព្រំដែនទូទាំងប្រទេស ចំពោះករណីនាំទារកចេញ ដោយត្រួតពិនិត្យឲ្យបានហ្មត់ចត់លើលិខិតបទដ្ឋានដែលបានប្រើប្រាស់ ជៀសវាងការផ្តល់ឱកាសឲ្យជនល្មើសប្រើជាមធ្យោបាយនាំទារកចេញដោយខុសច្បាប់ ។
- បន្ត និងពង្រឹងការតាមដានស៊ើបអង្កេតករណីសង្ស័យ ពាក់ព័ន្ធនឹងការបំផុសឲ្យមានការពពោះជំនួស ឬល្បិចកលក្នុងការនាំទារកចេញតាមមធ្យោបាយផ្សេងៗដែល គួរ

ឲ្យសង្ស័យ នៅតាមបណ្តាមូលដ្ឋាន បណ្តាច្រកទ្វារព្រំដែន ដើម្បីមានវិធានការតាមផ្លូវច្បាប់ ។

ទទួលបានគោលការណ៍ណែនាំនេះ សូមក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងអស់ ជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធាន គ.ជ.ប.ជ**



**សម្តេចក្រឡាហោម ស ខេង**